**សំបុត្រនៅថ្ងៃបុណ្យប៉ាស្កា**
**ពី ប៉ាទ្រីអាខ គីរីល នៃទីក្រុងម៉ូស្គូ និងប្រទេសរុស្ស៊ីទាំងអស់**
**ទៅកាន់គ្របប៊ីស្សព បូជាចារ្យ ឌីខិន សង្ឃ និងដូនជី ទាំងអស់**
**និងអ្នកមានជំនឿនៃព្រះសហគមន៍គ្រិស្តសាសនាអរតូដុក្សរុស្ស៊ីទាំងអស់**

**ប៊ីស្សពជាទីស្រឡាញ់ បូជាចារ្យនិងឌីកុនជាទីគោរពទាំងអស់**
**ព្រះសង្ឃ និង ដូនជីដែលស្រឡាញ់ព្រះជាម្ចាស់ទាំងអស់**
**និងបងប្អូនជាទីគោរពរាប់អាន!**

ខ្ញុំសូមជម្រាប់ទៅកាន់អ្នកទាំងអស់គ្នា គ្រិស្តបរិស័ទគ្រិស្តអរតូដុក្ស ដែលរស់នៅក្នុងប្រទេសជាច្រើននៃពិភពលោក ដែលឥឡូវនេះនៅក្នុងព្រះវិហារ ឬនៅតាមផ្ទះរបស់ខ្លួនសូមស្វាគមន៍មកកាន់ពិធីបុណ្យដ៏អស្ចារ្យគឺ បុណ្យប៉ាស្កាដ៏វិសុទ្ធ ដោយដួងចិត្តរបស់ខ្ញុំពោរពេញដោយ សេចក្តីអំណរខាងវិញ្ញាណ និងការប្រកាសដោយជ័យជំនះ ស្របតាមទំនៀមទម្លាប់បុរាណថាៈ

*ព្រះគ្រីស្ទបានរស់ឡើងវិញ!*

គឺពាក្យទាំងនេះហើយដែលព្រះសហគមន៍បានប្រកាសដោយជ័យ នូវដំណឹងដ៏រីករាយនៃសេចក្តីសង្គ្រោះ ដែលព្រះបានប្រទានឲ្យ អស់រយៈពេលពីរពាន់ឆ្នាំ។ នៅក្នុងពាក្យទាំងនេះ គឺជាភ្លើងនៃសេចក្តីជំនឿរបស់យើង កម្លាំងនៃសេចក្តីស្រឡាញ់ មូលដ្ឋានគ្រឹះនៃក្តីសង្ឃឹម មូលដ្ឋានគ្រឹះនៃព្រះសហគមន៍ បេះដូងនៃសារព្រះគម្ពីរសញ្ញាថ្មីទៅកាន់ពិភពលោក ពន្លឺដែលមិនរលត់នៃការត្រាស់ដឹង និងប្រភពនៃការបំផុសគំនិត ស្នូលនៃ ជីវិតគ្រីស្តបរិស័ទ និងអនាគតរបស់យើងទាំងមូល។

អ្វីៗក៏ដោយ ដែលកើតឡើងនៅក្នុងពិភពលោករបស់យើង គឺផ្លាស់ប្តូរជានិច្ច ជួនកាលគ្មានភាពស្ងប់ស្ងាត់ និងមានជម្លោះ ភាពលំបាក និងទុក្ខលំបាកណាមួយកើតឡើងចំពោះយើង យើងដឹង ជឿ និងផ្សព្វផ្សាយថា សេចក្តីអំណរនៃបុណ្យប៉ាស្កា នៅក្នុងព្រះអង្គសង្គ្រោះដែលរស់ឡើងវិញនៅតែមិនសាបសូន្យ និងពេញដោយជ័យជំនះ។

តើអ្វីទៅជាអត្ថន័យនៃបុណ្យគ្រិស្តសាសនិកដ៏អស្ចារ្យបំផុតនេះ? នៅក្នុងព្រះនាមនៃអ្វី និងហេតុអ្វីបានជាព្រះរាជបុត្រានៃព្រះយាងចុះមកផែនដី យកទម្រង់ជា *អ្នកបម្រើ* (ភីលីព ២: ៧) ស៊ូទ្រាំនឹងការរងទុក្ខ ត្រូវបានគេឆ្កាងនៅលើឈើឆ្កាង ហើយរស់ពីសុគតឡើងវិញ? ហើយ

តើយើងជាមនុស្សនៅសតវត្សរ៍ទី ២១ ត្រូវធ្វើអ្វីខ្លះដើម្បីក្លាយជាអ្នកចូលរួមពិត និងជាអ្នកទទួលមរតកនៃជ័យជម្នះរបស់ព្រះគ្រីស្ទលើសេចក្តីស្លាប់?

ព្រះសហគមន៍ផ្តល់ចម្លើយដល់យើងចំពោះសំណួរទាំងនេះ ដោយថ្លែងជាជាសក្ខីភាពថា តាមរយៈព្រះរាជបុត្រានៃព្រះដែលបានចាប់កំណើត នៃស្ត្រីព្រហ្មចារីដ៏មានពរបំផុត *នរកត្រូវបានចាប់ជាឈ្លើយសឹក។ អ័ដាមត្រូវបានបានលួសពីសេចក្ដីស្លាប់ បណ្ដាសា ត្រូវបានទុកជាមោឃៈ អេវ៉ាត្រូវបានរំដោះ សេចក្ដីស្លាប់ត្រូវបានសម្លាប់ ហើយយើងត្រូវ បានផ្តល់ដោយជីវិត* (ទេអូតូគីអូនសម្រាប់ថ្ងៃអាទិត្យ, ស្ទីខេរូន នៅក្នុងការសរសើរ, របៀបទី២)។ ពិតប្រាកដណាស់ ព្រះអម្ចាស់ប្រោសយើងឱ្យរស់ឡើងវិញដោយសេចក្តីស្រឡាញ់របស់ទ្រង់ រំដោះយើងពីការភ័យខ្លាចនៃសេចក្តីស្លាប់ និងភាពពុករលួយ ព្យាបាលភាពទន់ខ្សោយខាងវិញ្ញាណ និងរូបកាយរបស់យើង គាំទ្រយើងក្នុងការលំបាក និងការសាកល្បង លួងលោមយើងក្នុងទុក្ខវេទនា និងទុក្ខព្រួយ ហើយជួយយើងដើរតាមផ្លូវនៃសេចក្តីសង្គ្រោះដែលនាំទៅដល់ ជីវិតអស់កល្បជានិច្ច នៅពេលដែលព្រះជាម្ចាស់ *នឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់គេ សេចក្ដីស្លាប់លែងមានទៀត ហើយការកាន់ទុក្ខ ការសោកសង្រេងនិង ទុក្ខលំបាកក៏លែងមានទៀតដែរ ដ្បិត អ្វីៗដែលកើតមានកាលពី មុននោះបាត់អស់ទៅហើយ*»។(វិវរណៈ ២១:៤)

ដោយបានធ្វើកិច្ចការនៃការប្រោសលោះ តាមរយៈការបូជារបស់ទ្រង់នៅលើឈើឆ្កាង និងការរស់ឡើងវិញដ៏រុងរឿង ព្រះអម្ចាស់បានបើកទ្វារស្ថានសួគ៌ដល់មនុស្សគ្រប់រូប។ ចាប់ពីពេលនោះមក និងរហូតមកដល់សព្វថ្ងៃនេះ មនុស្សគ្រប់រូបត្រូវបានផ្តល់ឱកាសឱ្យឱបក្រសោបព្រះគ្រីស្ទដោយអស់ពីចិត្តជាព្រះពិត និងព្រះអង្គសង្គ្រោះ ដែលផ្តល់កម្លាំងពរសម្រាប់ការដឹកនាំជីវិតសុចរិត និងចូលរួមយ៉ាងសកម្មក្នុងការប្រែរូបរាងពិភពលោក។

ដោយឆ្លុះបញ្ចាំងពីពិធីបុណ្យ ប៉ាស្ការ សត្ត នីកូលាស នៃប្រទេសស៊ែប៊ី ដែលជាទេវវិទូដ៏លេចធ្លោម្នាក់នៃសតវត្សមុន គាត់បានសរសេរថា *ព្រះគ្រីស្ទបានរស់ឡើងវិញហើយ វាមានន័យថាជីវិតគឺខ្លាំងជាងសេចក្តីស្លាប់។ ព្រះគ្រីស្ទបានរស់ឡើងវិញ - វាមានន័យថាល្អគឺខ្លាំងជាងអាក្រក់។ ព្រះគ្រីស្ទបានរស់ឡើងវិញ - វាមានន័យថាការលំបាកទាំងអស់នៅក្នុងជីវិតត្រូវបានដោះស្រាយ* (ការគិតលើការល្អនិងអាក្រក់)។ ហើយសេចក្តីអំណរនៃបុណ្យប៉ាស្កានេះ ដែលជាសេចក្តីអំណរនៃការរួបរួមជាមួយនឹងព្រះជាម្ចាស់ និងការកសាង *ជីវិតថ្មី* (រ៉ូម ៦:៤) ដោយឈរលើមូលដ្ឋាននៃភាពល្អ និងយុត្តិធម៌ បានប៉ះពាល់ដល់ដួងចិត្តរបស់គ្រីស្ទបរិស័ទរាប់លាននាក់ ដែលបំផុសគំនិតពួកគេឱ្យធ្វើកិច្ចការសប្បុរសធម៌ និង សេចក្តីមេត្តាករុណា ជួយជម្នះទុក្ខ

លំបាក សម្រាលទុក្ខពួកគេក្នុងគ្រាលំបាក ផ្តល់ក្តីសង្ឃឹមដល់អ្នកដែលអស់សង្ឃឹម និងពង្រឹងដល់អ្នកដែលទន់ខ្សោយ។

នៅថ្ងៃបុណ្យប៉ាស្កា ដ៏ត្រចះត្រចង់នេះ ការអធិស្ឋានពិសេសរបស់យើងត្រូវបានថ្វាយដល់ព្រះជាម្ចាស់សម្រាប់ប្រជាជននៅក្នុងតំបន់សង្គ្រាម។ យើងជាគ្រិស្តសាសនិកមិនអាចនៅព្រងើយកន្តើយនឹងបញ្ហា និងភាពលំបាករបស់បងប្អូនប្រុសស្រីរបស់យើងដែលបេះដូងរបស់ពួកគេត្រូវបានឆេះដោយភ្លើងនៃជម្លោះរវាងគ្នាដែលបំផ្លាញពួកគេទាំងសងខាងនោះទេ។ ដូច្នេះយើងលើកពាក្យអង្វរដ៏ក្លៀវក្លារបស់យើងចំពោះព្រះអម្ចាស់ ដើម្បីឱ្យដោយ សេចក្តីមេត្តាករុណា និងសេចក្តីសប្បុរសរបស់ទ្រង់ ទ្រង់អាចប្រោសឱ្យ ជាខាងរូបកាយ និងលើអ្វីៗផ្សេងទៀត គឺរបួសខាងវិញ្ញាណ ផ្តល់ការលួងលោមក្នុងគ្រប់ ទាំងទុក្ខព្រួយ និងផ្តល់សេចក្តីសន្តិភាពដ៏ស្ថិតស្ថេរនិងយុត្តិធម៌ ដល់ប្រជាជនដែលជាបងប្អូន ដែលបានធ្វើពិធីជ្រមុខទឹកក្នុងទឹកតែមួយនៃទន្លេ ឌីនីភឺរ (Dnieper) ។

ជីវិតនៅលើផែនដីរបស់ព្រះអង្គសង្គ្រោះគឺពោរពេញដោយកម្លាំងពលកម្ម និងសេចក្តីស្រឡាញ់លះបង់សម្រាប់មនុស្ស ហើយយើងត្រូវបានហៅឱ្យក្លាយដូចជាទ្រង់ក្នុងការបម្រើអ្នកជិតខាងរបស់យើង ចាប់តាំងពីចំណុចណាមួយ សូម្បីតែគុណធម៌តូចបំផុតក៏ដោយ ការខិតខំប្រឹងប្រែងគ្រប់យ៉ាងដើម្បីយកឈ្នះលើភាពអាត្មានិយមរបស់យើងសម្រាប់ជាប្រយោជន៍ដល់មនុស្សផ្សេងទៀត ទាញយើងឱ្យខិតទៅជិតព្រះ ដែលជាប្រភពនៃជីវិត និងអមតៈ ដូច្នេះហើយវាធ្វើឱ្យយើងកាន់តែរីករាយ។

សូមព្រះអម្ចាស់ដែលមានព្រះជន្មរស់ឡើងវិញ ដែលស្របតាមការសន្យាដ៏ពិតរបស់ទ្រង់ គង់នៅជាមួយពួកអ្នកដើរតាមទ្រង់ *រហូតដល់ទីបញ្ចប់នៃពិភពលោក* (ម៉ាថាយ ២៨:២០) សូមប្រោសប្រទានពរដល់ពួកយើង ទាំងដែលយើងមានបាប និងទន់ខ្សោយ ប៉ុន្តែស្រេកឃ្លានសេចក្តីសុចរិត និងស្វែងរកសេចក្តីសង្គ្រោះ ដើម្បីទទួលជីវិតដ៏មានពរបន្ទាប់ពីយើងបំពេញដំណើរផែនដីរបស់យើង ដើម្បីនៅក្នុងវិមានសួគ៌ *ដែលបាន ត្រៀមចាំតាំងពីកំណើតនៃពិភពលោក* (ម៉ាថាយ ២៥:៣៤) យើងនឹង*រួមជាមួយនឹងពួកវិសុទ្ធ សោយរាជ្យក្នុងសិរីល្អដ៏អស់កល្បរបស់ទ្រង់* (សត្ត អាំប្រូស នៃស្រុកមីឡាន, ទំនុកតម្កើង "យើងសរសើរតម្កើងទ្រង់ ឱព្រះជាម្ចាស់អើយ")។ ការទន្ទឹងរង់ចាំដ៏រីករាយនៃព្រះរាជាណាចក្រនៃសេចក្តីស្រឡាញ់នឹងមកដល់ *ដែលព្រះជាម្ចាស់ជាអ្វីគ្រប់យ៉ាងសម្រាប់មនុស្សគ្រប់រូប* (១ កូរិនថូស ១៥:២៨) គឺជាអ្វីដែលព្រះសហគមន៍អធិប្បាយគ្រប់ពេលវេលា និងច្រើនជាងនេះទៅទៀតគឺនៅក្នុងរដូវបុណ្យប៉ាស្កាដ៏ត្រចះត្រចង់នេះ។

ចូរយើងស្តាប់តាមសំឡេងនៃសេចក្តីសង្គ្រោះនៃព្រះសហគមន៍ដែលហៅយើងតាមរយៈសាវ័កប៉ុលដ៏វិសុទ្ធ ដើម្បីអបអរបុណ្យប៉ាស្កា *ដោយមិនប្រើនំប៉ុងដែលមានមេ មេរ្យាចាស់ ឬមេនៃអំពើ អាក្រក់ និងអំពើថោកទាបនោះឡើយ គឺយើងប្រើនំប៉ុងឥតមេជា សញ្ញានៃចិត្តបរិសុទ្ធ និងចិត្តស្មោះត្រង់របស់យើង។* (១ កូរិនថូស ៥:៨) ចូរយើងស្តាប់ ហើយព្យាយាមរស់នៅតាមបញ្ញត្តិដ៏ទេវភាព ដោយសេចក្តីពិតនៃដំណឹងល្អ សូមឲ្យអំពើល្អរបស់យើង និងពេញមួយជីវិតរបស់យើង ធ្វើជាសាក្សីនៅចំពោះមុខមនុស្សគ្រប់គ្នាថា ព្រះគ្រីស្ទបានរស់ឡើងវិញពិតប្រាកដ និងទៅកាន់ទ្រង់គឺពេញដោយសិរីល្អ និង កិត្តិយស ហើយនិងការថ្វាយបង្គំ រហូតតរៀងទៅ។ អាម៉ែន។

*† គីរីល*

*ប៉ាទ្រីអាខ នៃទីក្រុងម៉ូស្គូ និងប្រទេសរុស្ស៊ីទាំងអស់*

*បុណ្យប៉ាស្ការ*
*គ.ស. ២០២៣*